# ព្រះរាជក្រឹត្យ
# ស្តីពីលក្ខន្តិកៈដោយឡែក
# នៃក្របខ័ណ្ឌគ្រូបង្រៀនកំរិតបឋម

នស/រកត/០៩០១/៣៤១

**យើង**

**ព្រះបាទសម្តេចព្រះនរោត្តមសីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/ នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ដែលប្រកាសអោយប្រើច្បាប់ ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំពីនាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០១។

## ប្រកាសបង្គាប់

### ជំពូក ទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

ត្រូវបានបង្កើតក្របខ័ណ្ឌ គ្រូបង្រៀនកំរិតបឋម ដែលត្រូវបានចាត់ថ្នាក់ក្នុងប្រភេទ គ ដូចមានចែងក្នុង មាត្រា៥ នៃព្រះរាជក្រឹត្យលេខ ជស-រកត ១២៩៧-២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពី គោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ។

**មាត្រា ២ .-**

ក្របខ័ណ្ឌ គ្រូបង្រៀនកំរិតបឋមស្ថិតក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា ប្រមូលផ្តុំគ្រប់មន្ត្រីបច្ចេកទេសខាងគរុកោសល្យ និង បច្ចេកទេស ផ្សេងទៀត ដែលបានបណ្តុះបណ្តាល ហើយកំពុងបំរើការនៅតាមគ្រឹះស្ថានសិក្សា សាធារណៈបឋមសិក្សា និងមត្តេយ្យសិក្សា និងតាមអង្គភាពជំនាញថ្នាក់កណ្តាល និង ខេត្ត ក្រុង នៃក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៣ .-**

ក្របខ័ណ្ឌគ្រូបង្រៀនកំរិតបឋម មានមុខងារក្នុងតំណែង ជាអ្នកបង្រៀន អ្នកសិក្សាស្រាវជ្រាវនិងមុខងារក្នុងតំណែងគ្រប់គ្រង ។

### ជំពូក ទី ២
### ឋានន្តរស័ក្តិ និង មុខតំណែង

**មាត្រា ៤ .-**

ក្របខ័ណ្ឌគ្រូបង្រៀនកំរិតបឋម មាន ៣ ឋានន្តរស័ក្តិ ៖

- ឋានន្តរស័ក្តិ ទី ១ ឬ គ្រូបង្រៀនកំរិតបឋម ដើមខ្សែពិសេស មាន ៦ ថ្នាក់
- ឋានន្តរស័ក្តិ ទី ២ ឬ គ្រូបង្រៀនកំរិតបឋម ដើមខ្សែ មាន ១០ ថ្នាក់
- ឋានន្តរស័ក្តិ ទី ៣ ឬ គ្រូបង្រៀនកំរិតបឋម មាន ១៤ ថ្នាក់ ។

**មាត្រា ៥ .-**

គ្រូបង្រៀនកំរិតបឋមមានឧបនិស្ស័យអាចកាន់មុខតំណែងគ្រប់គ្រងនៃក្រសួងអប់រំ យុវជន និងកីឡា ដូចខាងក្រោម ៖

- នាយករងសាលាបឋមសិក្សា
- នាយករងសាលាមត្តេយ្យសិក្សា ។ល។

និងមុខតំណែងឯទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ក្រសួងអប់រំ យុវជន និង កីឡា ។

## ជំពូក ទី ៣
## ការជ្រើសរើស

**មាត្រា ៦ .-**

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌគ្រូបង្រៀនកំរិតបឋម ត្រូវធ្វើឡើងតាមការប្រលងជ្រើសរើស ក្នុងចំណោមបេក្ខជនជាសិស្ស និស្សិត ។

ចំនួនតំណែងក្នុងការជ្រើសរើសសំរាប់បេក្ខជន ជាសិស្សនិស្សិត ត្រូវកំណត់ឡើងដោយរាជរដ្ឋាភិបាលតាមសំណើរបស់ ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៧ .-**

ការប្រលងជ្រើសរើសក្នុងចំណោមសិស្សនិស្សិត ត្រូវបើកទូលាយចំពោះបេក្ខជនដែលមានអាយុច្រើនបំផុត ២៥ឆ្នាំ គិតមកដល់ថ្ងៃប្រលង ហើយដែលមានសញ្ញាប័ត្រទាបបំផុត សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ឬ សញ្ញាប័ត្រសមមូល ។ អាយុនេះអាចរំកិលពី ២៥ ដល់ ៣០ ឆ្នាំ ស្របតាមមាត្រា១១ នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

ការប្រលងជ្រើសរើសក្នុងចំណោមសិស្ស និស្សិត ត្រូវឆ្លងកាត់ការពិនិត្យសុខភាព និងកាយសម្បទាមុននឹងចូលរៀននៅសាលាបណ្តុះបណ្តាល ។

លក្ខណៈវិនិច្ឆ័យកាយសម្បទា ត្រូវកំណត់ដោយក្រសួងអប់រំ យុវជន និង កីឡា ។

## ជំពូក ទី ៤
## ការបណ្តុះបណ្តាលដំបូង កម្មសិក្សាសាកល្បង និង ការតាំងស៊ប់

**មាត្រា ៨ .-**

បេក្ខជនដែលបានជ្រើសរើសតាមរយៈការប្រលងជ្រើសរើស ក្នុងចំណោមសិស្សនិស្សិតមានឋានៈជាគរុសិស្សកំរិតបឋម ហើយត្រូវទទួលការបណ្តុះបណ្តាលដំបូងរយៈពេលខ្លីដែលរៀបចំដោយ ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៩ .-**

បន្ទាប់ពីការបណ្តុះបណ្តាលដំបូង គ្រូបង្រៀនកំរិតបឋម ត្រូវបានបែងចែកអោយទៅបំរើការងារនៅតាមខេត្ត ក្រុង ហើយត្រូវបានតែងតាំងជាគ្រូបង្រៀនកំរិតបឋម កម្មសិក្សាតាមប្រកាសរបស់ ក្រសួងអប់រំ៹ន.

យុវជន និង កីឡា ។

គ្រូបង្រៀនកីឡាបឋមដែលជ្រើសរើសចេញពីសិស្ស និស្សិតត្រូវឆ្លងកាត់កម្មសិក្សាមួយដែលមានរយៈពេល១២ខែ ។ រយៈពេលកម្មសិក្សាត្រូវបានអនុវត្តចាប់ពីពេលប្រលងជ្រើសរើសជាប់ ។ក្រោយពេលធ្វើកម្មសិក្សាសាកល្បង មន្ត្រីដែលត្រូវបានជ្រើសរើសចេញពីសិស្សនិស្សិតត្រូវបានតាំងស៊ប់ក្នុងថ្នាក់លេខ ១៤ នៃឋានន្តរស័ក្តិ ទី ៣ ។

គ្រូបង្រៀនកីឡាបឋមដែលធ្វើកម្មសិក្សាធ្លាក់ត្រូវអនុញ្ញាតអោយបន្តកម្មសិក្សានៅឆ្នាំទី ២ទៀត ។ ក្នុងករណីធ្លាក់កម្មសិក្សានៅឆ្នាំទី ២ នេះកម្មសិក្សាការី ជ្រើសរើសចេញមកពីសិស្សនិស្សិត ត្រូវលុបឈ្មោះចោល ។

ការតាំងស៊ប់ក្នុងឋានន្តរស័ក្តិទី ៣ នៃគ្រូបង្រៀនកីឡាបឋម ត្រូវធ្វើឡើងដោយ ប្រកាស ។

## ជំពូក ទី ៥

## ការតែងតាំង

**មាត្រា ១០ .-**

ក្រោយពេលត្រូវបានតាំងស៊ប់ក្នុងក្របខ័ណ្ឌរួចហើយ គ្រូបង្រៀនកីឡាបឋមត្រូវបានតែងតាំងអោយបំពេញមុខងារក្នុង មុខតំណែង ដូចមានចែងក្នុងមាត្រា ៣ ឬ អាចត្រូវបានតែងតាំងក្នុងមុខតំណែងគ្រប់គ្រងទំនេរណាមួយ ដូចមានចែងក្នុងមាត្រា៥ ខាងលើ ។

## ជំពូក ទី ៦

## ការដាក់អោយស្ថិតនៅក្រៅក្របខ័ណ្ឌដើម

**មាត្រា ១១ .-**

គ្រូបង្រៀនកីឡាបឋម អាចដាក់អោយស្ថិតនៅក្រៅក្របខ័ណ្ឌដើម ឬក្រៅតំណែងដើម្បីបំរើការនៅក្រសួងស្ថាប័នមួយផ្សេងទៀតតាមតំរូវការ និងតាមការយល់ព្រមពីសាមីជន ។

## ជំពូក ទី ៧

## ការតម្លើងថ្នាក់ និង ការតម្លើងឋានន្តរស័ក្តិ

**មាត្រា ១២ .-**

គ្រូបង្រៀនកីឡាបឋម ត្រូវបានតម្លើងថ្នាក់ក្នុងឋានន្តរស័ក្តិណាមួយ ទៅតាមលក្ខខណ្ឌដូចបានចែងក្នុងមាត្រា ២០ និង មាត្រាបន្តបន្ទាប់ នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

លក្ខណៈសម្បត្តិជាមូលដ្ឋាន ដែលត្រូវពិនិត្យតម្លើងថ្នាក់មានដូចខាងក្រោម ÷

- គំនិតផ្តួចផ្តើមច្នៃប្រឌិត និង លទ្ធផលការងារ
- មនសិការវិជ្ជាជីវៈ ស្មារតីទទួលខុសត្រូវ វិន័យការងារ។ល។

- ការយកចិត្តទុកដាក់ដល់ផលប្រយោជន៍ជាតិ
- សាមគ្គីភាព សីលធម៌រស់នៅ សកម្មភាពសង្គម ។

ការតម្លើងថ្នាក់ នៃអ្នករាជការក្នុងក្របខ័ណ្ឌនេះ ត្រូវគិតក្នុងសមាមាត្រ ៣ ភាគ ៤ ក្នុងវេនជ្រើសរើស និង ១ ភាគ ៤ តាមវេនអតីតភាព ។

**មាត្រា ១៣ .-**

គោលការណ៍ នៃការតម្លើងឋានន្តរស័ក្តិ ត្រូវតម្លើងទៅក្នុងថ្នាក់ដំបូង នៃឋានន្តរស័ក្តិខ្ពស់លើបន្ទាប់ ឬក្នុងករណីចាំបាច់ ត្រូវតម្លើងទៅក្នុងថ្នាក់ដែលស្របជាមួយសន្ទស្សន៍ខ្ពស់លើបន្ទាប់ពីសន្ទស្សន៍ចាស់របស់មន្ត្រីសាមី ។

ការតម្លើងឋានន្តរស័ក្តិ ត្រូវអនុវត្ត តាមគោលការណ៍ភាគរយ ដោយត្រូវបានកំណត់ តាមសមាមាត្រ ៧០% សំរាប់ឋានន្តរស័ក្តិទី៣ ២៥%សំរាប់ឋានន្តរស័ក្តិទី២ និង៥%សំរាប់ឋានន្តរស័ក្តិទី១ ។ ការតម្លើងឋានន្តរស័ក្តិនេះត្រូវធ្វើតាមរយៈការចុះឈ្មោះក្នុងតារាងតម្លើងឋានន្តរស័ក្តិ និងការវាយតំលៃរបស់ឋានានុក្រម គ្រប់គ្រង ឬ តាមរយៈការបណ្តុះបណ្តាល និងវិក្រឹតការជំនាញនៅក្នុង ឬ ក្រៅប្រទេស ។

ការតម្លើងថ្នាក់ និង តម្លើងឋានន្តរស័ក្តិ នៃគ្រូបង្រៀនកំរិតបឋម ត្រូវសំរេចដោយប្រកាសរបស់ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ១៤ .-**

អាចតម្លើងទៅក្នុងឋានន្តរស័ក្តិ គ្រូបង្រៀនកំរិតបឋមដើមខ្សែ គឺ គ្រូបង្រៀនកំរិតបឋមទាំងឡាយដែលបានឡើង ដល់ថ្នាក់ លេខ ១១ ឡើងទៅក្នុងឋានន្តរស័ក្តិទី ៣ នៃក្របខ័ណ្ឌគ្រូបង្រៀនកំរិតបឋម ។ អាចតម្លើងទៅក្នុងឋានន្តរស័ក្តិ គ្រូបង្រៀនកំរិតបឋមដើមខ្សែពិសេស គឺគ្រូបង្រៀនកំរិតបឋមទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ៧ ឡើងទៅនៃឋានន្តរស័ក្តិ គ្រូបង្រៀនកំរិតបឋមដើមខ្សែ ។

**មាត្រា ១៥ .-**

សន្ទស្សន៍សំរាប់ថ្នាក់ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌគ្រូបង្រៀនកំរិតបឋម និង តំលៃឯកតានៃសន្ទស្សន៍ ព្រមទាំងកំរិត លាភការផ្សេងៗទៀត ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក ។

## ជំពូក ទី ៨

## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១៦ .-**

ក្នុងករណីចាំបាច់ លក្ខខ័ណ្ឌដោយឡែក នៃការប្រលងជ្រើសរើសគ្រូបង្រៀនកំរិតបឋមសំរាប់ខេត្ត ក្រុង ដាច់ស្រយាល និងតំបន់ជួបការលំបាកត្រូវកំណត់ដោយរាជរដ្ឋាភិបាល ។៚.

**មាត្រា ១៧ .-**

មន្ត្រីរាជការក្នុងក្របខ័ណ្ឌគ្រូបង្រៀនកីឡាតបឋម ត្រូវទទួលប្រាក់កំរៃគរុកោសល្យ ជាប្រាក់រង្វាន់នៃមុខតំណែងគ្រូបង្រៀន ។

**មាត្រា ១៨ .-**

គ្រូបង្រៀនកីឡាតបឋមដែលក្រសួងចាត់អោយទៅទទួលការបំប៉ន ឬការបណ្តុះបណ្តាលបន្ថែមរយៈពេលសរុបយ៉ាងតិច ៦ ខែ នៅក្នុងជំនាញ ដែលបំរើអោយវិស័យអប់រំ យុវជន និង កីឡា ដោយមានវិញ្ញាបនប័ត្រ ឬលិខិតបញ្ជាក់ការសិក្សាត្រូវបានទទួលការតម្លើងថ្នាក់ ១ ថ្នាក់ ជាស្វ័យប្រវត្តិតាមវេនជ្រើសរើស ។

ចំពោះគ្រូបង្រៀនកីឡាតបឋម ដែលត្រូវបានក្រសួងចាត់អោយទៅបន្តសិក្សា ឬ បំប៉នជំនាញផ្សេងៗ រយៈពេលសិក្សានោះត្រូវបានគិតសំរាប់ការតម្លើងឋានន្តរស័ក្តិ ឬ ឡើងថ្នាក់ ។

**មាត្រា ១៩ .-**

ពេលចូលបំរើការដំបូង ឬ ក្នុងពេលបំរើការ គ្រូបង្រៀនកីឡាតបឋមដែលមានសញ្ញាប័ត្រខ្ពស់ជាងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ត្រូវបានតម្លើងថ្នាក់ជាស្វ័យប្រវត្តិ ១ ថ្នាក់ សំរាប់សញ្ញាប័ត្រមធ្យមសិក្សាបច្ចេកទេស និង ២ ថ្នាក់ សំរាប់បរិញ្ញាប័ត្រ ឬ សញ្ញាប័ត្រសមមូល ។

**មាត្រា ២០ .-**

គ្រូបង្រៀនកីឡាតបឋម បំរើការរហូតដល់អាយុ ៦០ ឆ្នាំ ទើបចូលនិវត្តន៍ ។

ការដាក់អោយចូលនិវត្តន៍ ត្រូវសំរេចដោយប្រកាសរបស់ក្រសួង អប់រំ យុវជន និង កីឡា ។

## ជំពូក ទី ៩
## អន្តរប្បញ្ញត្តិ

**មាត្រា ២១ .-**

ចំនួនមន្ត្រី នៃក្របខ័ណ្ឌគ្រូបង្រៀនកីឡាតបឋម ត្រូវកសាងចេញពីសមាហរណកម្ម គ្រូបឋមសិក្សា និងគ្រូមត្តេយ្យសិក្សាប្រភេទ ខ III ដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌ ក្នុងគ្រឹះស្ថានសិក្សាសាធារណៈនិងក្នុងអង្គភាពជំនាញថ្នាក់កណ្តាល និងតាម ខេត្ត ក្រុង របស់ក្រសួងអប់រំ យុវជន និង កីឡា ។

ដោយឡែក ចំពោះគ្រូបឋមសិក្សា និងគ្រូមត្តេយ្យសិក្សា ប្រភេទ ខ IV ក្រសួងអប់រំ យុវជន និង កីឡា ត្រូវរៀបចំអោយមានការប្រលងផ្ទៃក្នុង ១ ឆ្នាំម្តង ទៅជាគ្រូបឋមសិក្សា និងគ្រូមត្តេយ្យសិក្សាប្រភេទ ខ III ។ ការប្រលងផ្ទៃក្នុងនេះត្រូវអនុវត្តអោយចប់ក្នុងរយៈពេល ៣ ឆ្នាំ គិតពីពេលព្រះរាជក្រឹត្យនេះ ចូលជាធរមាន ។

អ្នកប្រលងជាប់ត្រូវធ្វើសមាហរណកម្មទៅក្របខ័ណ្ឌគ្រូបង្រៀនបឋមសិក្សា ។ អ្នកប្រលងធ្លាក់ទាំង ៣ លើក ត្រូវធ្វើសមាហរណកម្មទៅក្នុងក្របខ័ណ្ឌប្រភេទ ឃ របស់មុខងារសាធារណៈ ។/.

មាត្រា ២២ .-

គ្រូបង្រៀនកីឡាតបឋម ដែលត្រូវបានតែងតាំងរួចហើយ ក្នុងមុខតំណែងគ្រប់គ្រងណាមួយត្រូវបាន អនុញ្ញាតអោយបន្តមុខតំណែងរបស់ខ្លួន លើកលែងតែមានការចាំបាច់ ត្រូវផ្លាស់ប្តូរមុខតំណែងដែលជាសមត្ថកិច្ច របស់ក្រសួង អប់រំ យុវជន និង កីឡា។

## ជំពូក ទី ១០

## អវសានប្បញ្ញត្តិ

មាត្រា ២៣ .-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ២៤ .-

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជ ក្រឹត្យនេះ ។

មាត្រា ២៥ .-

ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។ល។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ ២០០១

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ៧៣៥ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**[illegible] តាន់**